# មន្ទីរកសិកម្មខេត្តកណ្ដាល

# ដង្កូវស៊ីរូងដើម



អាស័យដ្ឋានទំនាក់ទំនង ផ្លូវលេខ ១០៣ (តាខ្មៅ)
ទំនាក់ទំនងទូរស័ព្ទ (០២៣ ៩៨៣ ៤៦១)
(០១២ ៨២៤ ៤២៥)

ឧបត្ថម្ភដោយៈ អង្គការវីវីអូប៊ី VVOB

vvob education for development

ឆ្នាំ ២០១០

# ដង្កូវស៊ីរូងដើម

## ១-លក្ខណៈទូទៅ

មេអំបៅដង្កូវស៊ីរូងដើមមាន ៤ប្រភេទគឺៈ មេអំបៅឆ្នូត (1) មេអំបៅស (2) មេអំបៅលឿង (3) និងមេអំបៅផ្កាឈូក ឬពណិស៊ីជំពូ (4)។ មេអំបៅស កំរជួបប្រទះណាស់នៅប្រទេសកម្ពុជា ប៉ុន្តែ ៣ប្រភេទទៀត គេប្រទះឃើញជាញឹកញាប់។ ការបំផ្លាញកើតចេញអំពីដង្កូវរបស់វា ដែលរកស៊ីចិញ្ចឹមជីវិតនៅក្នុងដើមស្រូវ ហើយធ្វើឱ្យខូចប្រព័ន្ធសសៃដើមស្រូវ។ ការបំផ្លាញរបស់ដង្កូវស៊ីរូងដើមមានរយៈពេលពី ២២-៣០ថ្ងៃ។




## ២-លក្ខណៈរូប

-ពង ជាកញ្ចុំដែលមានចំនួន ៥០-២៥០ពង ស្ថិតនៅលើផាងស្លឹក ឬនៅចន្លោះស្រទបស្លឹក និងដើម និងមានពណិពីសទៅលឿង និងទៅជាខ្មៅនៅពេលជិតញាស់ (មានរោមឆ្មាៗគ្របការពារពីលើ)។

-ដង្កូវ ពេលញាស់ភ្លាមមានពណិស និងប្រែទៅជាពណិស៊ីជំពូលឿង ត្នោត ទៅតាមប្រភេទរបស់វានៅថ្ងៃបន្តបន្ទាប់។ ដង្កូវពេញរូបរាងមានប្រវែងខ្លួនពី ២,៥ ស.ម -៣,៥ ស.ម (វារស់នៅក្នុងដើមស្រូវ)។

-ដឹកឌឿ រស់នៅគល់នៃដើមស្រូវ មានពណិលឿងចាស់ ឬពណិត្នោត។

-មេអំបៅ ទុំនៅលើស្លឹក ឬលើដើមស្រូវ មានពណិលឿងដូចពណិកាកអំពៅ និងមានចំណុចពណិខ្មៅចំនួន ២ នៅលើស្លាបទាំងសងខាង ។

## ៣-វដ្តជីវិត

| ឈ្មោះដង្កូវស៊ីរូងដើម | ពង | ដង្កូវ | ដឹកឌឿ | មេអំបៅ | សរុប |
|---|---|---|---|---|---|
| ពណិលឿងនិងពណិស | ៨ថ្ងៃ | ៣០ថ្ងៃ | ៨ថ្ងៃ | ៧ថ្ងៃ | *៥៣ថ្ងៃ* |
| ពណិឆ្នូត | ៥ថ្ងៃ | ២៥ថ្ងៃ | ៥ថ្ងៃ | ៥ថ្ងៃ | *៤០ថ្ងៃ* |
| ពណិផ្កាឈូកឬស៊ីជំពូ | ៥ថ្ងៃ | ២២ថ្ងៃ | ៨ថ្ងៃ | ៨ថ្ងៃ | *៤៣ថ្ងៃ* |




## ៤-ដំណាក់កាលបំផ្លាញ

ដង្កូវស៊ីរូងដើម បំផ្លាញដំណាំស្រូវយ៉ាងខ្លាំងក្លា ក្នុងចំណោមសត្វល្អិតចង្រៃទាំងឡាយ ដែលគេប្រទះឃើញវារាតត្បាតនៅ